# Terminal 117 Cleanup

Port of Seattle and City of Seattle

## សេចក្តីសង្ខេបនៃគំរោង

ផ្នែកសម្អាតចំណតលេខ 117 (T-117) ដែលមានទីតាំងស្ថិតនៅច្រាំងទន្លេខាងលិចនៃ Lower Duwamish Waterway នៅ South Park គឺជាគំរោងបោសសម្អាតរួមមួយដោយកំពង់ផែរដ្ឋសេអាតថល (Port of Seattle) និង ទីក្រុងសេអាតថល (City of Seattle) ។ ផ្នែកនេះត្រូវបានកំណត់សម្រាប់ការសម្អាតដំបូង (មុនការសម្អាតទន្លេធំជាងនេះ) ដោយសារបរិវេណខ្ពង់រាប ច្រាំងទន្លេ និងកាកសំណល់ផ្សេងៗ នៅក្នុងផ្លូវទឹក មានកំហាប់ខ្ពស់នៃ PCPs (ប៉ូលីក្លូរីណាត ប៊ីផេនីល) ឌីអុកស៊ីន/ហ្វូរ៉ាន និងជាតិពុលដទៃផ្សេងទៀត ។ T-117 ត្រូវបានកំណត់ថាជាតំបន់ប្រតិបត្តិការដំបូង ដូចផ្នែកនៃ Lower Duwamish Waterway Superfund Site ដែលបានចុះបញ្ជីដោយទីភ្នាក់ងារការពារបរិស្ថាន (Environmental Protection Agency - EPA) សហរដ្ឋអាមេរិក ដែលស្ថិតនៅក្រោមច្បាប់នៃការឆ្លើយតប សំណង និង ការទទួលខុសត្រូវស្តីពីបរិស្ថានទូទៅ (Comprehensive Environmental Response, Compensation and Liability Act - CERCLA) ។

កំពង់ផែ និងទីក្រុងកំពុងរៀបចំផែនការពីវិធីដែលការសម្អាត T-117 នឹងត្រូវកើតមានឡើង ។ ឯកសារមួយដែលមានឈ្មោះថា ការវាយតម្លៃវិស្វកម្ម និងការវិភាគថ្លៃដើម (Engineering Evaluation and Cost Analysis - EE/CA) ផ្តល់ជូននូវព័ត៌មានលំអិតអំពីលក្ខណៈ និងវិសាលភាពជាតិពុលនៅតំបន់នោះ និងជម្រើសពីរបៀបធ្វើការសម្អាត ។ យើងខ្ញុំរំពឹងទុកថា EE/CA នឹងអាចទទួលបានសម្រាប់សាធារណៈជនពិនិត្យមើលឡើងវិញ និងឱ្យជាមតិយោបល់នៅក្នុងខែឧសភា នៃឆ្នាំនេះ ។ EPA កំពុងដឹកនាំ និងត្រួតពិនិត្យការសម្អាត T-117 និងទទួលខុសត្រូវសម្រេចផែនការសម្អាតនេះ ។ ក្នុងឋានៈជាដៃគូនៅក្នុងការបោសសម្អាត T-117 នេះ ក្រសួងបរិស្ថានប្រចាំរដ្ឋ (State Department of Ecology) កំពុងតែផ្តល់ជូនឱ្យក្រសួងដៃគូពិនិត្យមើលឡើងវិញ និងចូលរួមមតិយោបល់ ចំពោះសកម្មភាពសម្អាតផ្សេងទៀត ដែលត្រួតពិនិត្យប្រភពជាតិពុលទៅកាន់ទន្លេ ។